# ដំណាំល្ពៅ

## I. ស្ថានភាពទូទៅ

ល្ពៅជាប្រភេទដំណាំបន្លែម្យ៉ាង ដែលដុះលូតលាស់នៅលើពិភពលោកជា ច្រើនពាន់ឆ្នាំមកកន្លងមក ហើយម្យ៉ាងទៀតវាក៏ត្រូវបាន គេប្រើប្រាស់ជាបន្លែដ៏មាន ប្រជាប្រិយភាព នៅក្នុងជីវភាពប្រចាំថ្ងៃ ។ គេបានបែងចែកល្ពៅជាពីរប្រភេទគឺ:

- ល្ពៅផ្លែទ្រមៀចល្ពៅ
- ផ្លែវែង ឬ ល្ពៅទ្រូ

យោងតាមលទ្ធផលវិភាគក្នុងឆ្នាំ ១៩៧២ ដោយអង្គការ FAO និងនាយកដ្ឋានអប់រំសុខភាពសាធារណៈ នៃសហរដ្ឋអាមេរិក នៅលើផ្នែកប្រើប្រាស់ជាបន្លែក្នុងទម្ងន់ ១០០ង ដែលអាចបរិភោគបានមានក្នុងតារាងក្រោម





## តារាងអាហារូបត្ថម្ភ ១០០g បរិភោគបាន

| សារធាតុសំខាន់ៗ | ១០០g ចំអិន | |
|---|---|---|
| | ទង និង ផ្កា | ផ្លែ |
| ថាមពល | ២១ កាឡូរី | ២៧ កាឡូរី |
| ជាតិទឹក | ៩២% | ៩១.៩% |
| ប្រូតេអ៊ីន | ៣.០g | ០.៧g |
| ប្រេង | ០.៤g | ០.២g |
| ការបូអ៊ីដ្រាត | ៣.០g | ៦.៦g |
| ជាតិសរសៃ | ០.៧g | ០.៨g |
| ជាតិផេះ | ១.០g | ០.៦g |
| Ca | ៣៧mg | ២៤mg |
| P | ៩៩mg | ៣៣mg |
| Fe | ២.១០mg | ០.៧mg |
| Na | ៦.០mg | ៨.០mg |
| K | ៤៧២mg | ៣៥០mg |
| ការ៉ូតែន | ១៩៤០mcg | ៧៨៥mcg |

ក្រៅពីនេះវាមានសារធាតុរ៉ែ និងវីតាមីនជាច្រើនទៀតដូចជា វីតាមីន B ជាពិសេស គឺប្រភពវីតាមីន A ល្ពៅអាចដុះលូតលាស់បាន ពីតំបន់វាលទំនាបរហូតដល់ខ្ពង់រាប ។ ក្នុងករណីសីតុណ្ហភាពសមស្របធ្វើឱ្យបរិមាណផ្កាឈ្មោល និងបរិមាណផ្កាញីមាន អត្រាប្រហែលគ្នាការពោយលំអងពីកេសរឈ្មោលទៅកេសរញីបានលឿន ធ្វើឱ្យការបន្តពូជប្រព្រឹត្តទៅបានល្អ ។

ម្យ៉ាងវិញទៀតដំណាំប្រភេទ នេះមិនទាមទារនូវសក្តានុពលនៃដីជាតិដីខ្លាំងក្លានោះឡើយគេចាត់បញ្ចូលទៅក្នុងក្រុមធន់ទ្រាំនឹងដី អាស៊ីតវាអាចដុះលូតលាស់ បានលើដីដែលមាន pH ៥,៥-៧,០ ហើយជ្រាបទឹកបានល្អ វាមិនទាមទារនូវអត្រា សំណើមខ្ពស់ដូចដំណាំឯទៀត ប៉ុន្មានទេ ព្រោះថាបើសំណើមកើនឡើងធ្វើឱ្យងាយ នឹងកើតជំងឺផ្សេងៗនៅលើដើម និងស្លឹក ។

## II. បច្ចេកទេសដាំដុះ

១. ការជ្រើសរើសពូជ

នៅក្នុងវិស័យដាំដុះពូជជាកត្តាសំខាន់ជាងគេ ដូចនេះការជ្រើសរើសពូជត្រូវ អនុលោមនៅតាម លក្ខណៈសំខាន់ៗ ដូចខាងក្រោម:

ក. អំពីប្រភេទពូជ ពូជល្ពៅដែលប្រជាកសិករកំពុងធ្វើការដាំដុះមាន៤ យ៉ាងគឺ:

ល្ពៅក្អែក សំបកមានពណ៌ខ្មៅ ផ្លែមូលទ្រមៀចតូច សាច់ពណ៌លឿងចាស់ ហើយក្រាស់ គ្រាប់តូចមូលៗសាច់ល្អិត ពូជនេះ



នឹងផ្លែច្រើនក្នុងមួយដើមៗវាមានទង ផ្លែតូចខ្លី ស្លឹកតូចល្អិត ហើយមានរោមច្រើន គេឱ្យឈ្មោះថាល្ពៅភ្នំ ។ ប្រភេទពូជនេះ ធន់ទ្រាំគេអាចដាំនៅ រដូវភ្លៀងបានព្រោះវាធន់ទ្រាំនៅនឹងអាកាសធាតុក្តៅហើយមានអាយុកាលលូតលាស់ខ្លី។

ល្ពៅពួង: សំបកពណ៌ប្រផេះធម្មតា ផ្លែតូចទ្រមៀចទងធំៗ កទងវែងដើម តូចល្អិត ថ្នាំងរង្វើល ស្លឹកតូចមូលរោមស្តើងហើយទន់ ស្លឹកបៃតងខ្ចី សាច់ហាប់ណែន ពណ៌លឿង ប៉ុន្តែផ្អែម គ្រាប់តូចសំប៉ែតសាច់មានសរសៃបន្តិច ។ ពូជនេះភាគច្រើន ដាំនៅតំបន់ខ្ពង់រាប និង វាលរាបហើយនៅរដូវវស្សាវាធន់ទ្រាំទៅនឹងអាកាសធាតុ ក្តៅគេហៅថាល្ពៅល្អិត ឬល្ពៅពួង ។



ល្ពៅទ្រូ ឬល្ពៅហាប ពូជនេះមានស្លឹកធំ ដើមធំថ្លោស ទងស្លឹកវែងៗ ស្លឹកធំ មូលទ្រវែង ហើយស្តើងពណ៌បៃតងខ្ចី ផ្លែរង្វើលធំ សាច់ស្តើង សំបកពណ៌ប្រផេះ ខ្លះមូលទ្រវែង ស្រួចក្បាល ស្រួចកន្ទុយ សាច់ពណ៌លឿងភាវ ហើយមានសរសៃច្រើន មិនហាប់ មិនល្អិតហើយ មានជាតិផ្អែមទាប គ្រាប់របស់វាធំសំប៉ែតវែង ។ ពូជប្រភេទនេះគេច្រើនតែដាំនៅតាមតំបន់វាលទំនាប និងរដូវទឹកសំរក ព្រោះវាមិន ធន់ទ្រាំ នឹងអាកាសធាតុក្តៅ ។

ខ. លក្ខខណ្ឌនៃការជ្រើសរើស

ការជ្រើសរើសសម្រាប់ការដាំដុះត្រូវគិតពីលក្ខណៈសំខាន់ៗដូចតទៅ ពូជបង្កាត់ពូជHybrid $F_1$ ជាពូជដែលផ្តល់ផលខ្ពស់ពូជបង្កាត់សេរីOPV ឬពូជប្រពៃណីអាចទុកបន្តពូជទៅជំនាន់ក្រោយទៀត ប៉ុន្តែកំរិតទិន្នផលទាបជាងពូជបង្កាត់។





ជាពិសេស គឺពូជដែលផ្តល់ទិន្នផលខ្ពស់ សមស្របតាមតំបន់ ធន់ទ្រាំជម្ងឺសត្វល្អិត បំផ្លាញ ភាគរយនៃដំណុះគ្រាប់លើសពី ៨០% ។

២.ការរៀបចំដី

ល្ពៅអាចឆ្លើយតបទៅនឹងដីស្ទើរគ្រប់ប្រភេទ ប៉ុន្តែដីដែលមានជីជាតិទាបធ្វើល្ពៅឆាប់ងាប់ដើម ។ ប្រភេទដីដែលអំណោយផលដល់ ដំណាំល្ពៅ គឺដីល្បប់ល្បាយខ្សាច់ ដីប្របហម ឬដីខ្មៅ ប៉ុន្តែដីដែលជ្រាបទឹកមិនល្អ មិនអាចឱ្យល្ពៅទទួលបានទិន្នផលខ្ពស់ឡើយ ។



ដើម្បីដាស់ដំណេកគ្រាប់ពូជ ហើយដាក់ត្រាំទឹកមួយយប់ក្រោយមកយកគ្រាប់ពូជទៅលាយជាមួយនឹងថ្នាំសម្លាប់ផ្សិតបន្តិចៗដូចជា Mancozed, Zineb ឬ Orthocide ក្នុងកំរិត ៣g = ១ គ.ក្រ គ្រាប់ពូជ ។ គេអាចយកគ្រាប់ល្ពៅទៅដាំក្នុងរណ្តៅដែលបានកាប់ទុកជាមុនចំនួន ៣-៤ គ្រាប់ជម្រៅ ២-៣ សង់ទីម៉ែត្រ ក្នុង ១ ហិចតា គេដាំ ចំនួន ៤៥៦៥ រណ្តៅ ឬ គុម្ពដោយប្រើគ្រាប់ពូជចំនួន ៤-៥ គ.ក្រ ។

### ៤. ការជ្រំជ្រោយដី

ជ្រំជ្រោយដីមានសារៈប្រយោជន៍ធ្វើឱ្យដីធូរបន្ថយនៃការដុះស្មៅ បង្កឱ្យដីមាន សំណើមគ្រប់គ្រាន់ងាយស្រួលដល់ការដុះលូតលាស់ ព្រមទាំងបំបាត់ជំរកសត្វផ្សេងៗ គេជ្រំដោយចបដើម្បីបំផុសដី និងពូនគល់ក្រោយដីដាំរយៈពេល ១៥-២០ថ្ងៃ ។ ពេលនោះគេអាចដករំលោះ កូនចេញ ដោយទុកតែ ២-៣ ដើមក្នុង ១គុម្ព ។

### ៥. ការប្រើប្រាស់ជី

ដើម្បីឱ្យការលូតលាស់បានលឿន និងការបន្តពូជបានល្អគេត្រូវបែងចែកការដាក់ជីជា៣លើក: លើកទី១ យកជី ១៥,១៥,១៥ ចំនួន ១០០ គីឡូក្រាម លើផ្ទៃដី១ហិកតា មកដាក់រោយជុំវិញគល់ចំងាយ ២០-៣០ សង់ទីម៉ែត្រ មុនពេលជ្រំជ្រោយដីលប់ គល់បន្ទាប់មកជ្រំដីលប់ និងពូនគល់ឡើង ។ លើកទី២ យកជីហ៊ុយរ៉េមកលាយជាមួយទឹក ហើយស្រោចឱ្យជោគជុំវិញ គល់ដោយប្រើ ១៥-២០ ក្រាម លាយទឹក ១៨-២០ លីត្រ ។ សម្រាប់ផ្ទៃដីមួយ



ម្យ៉ាងទៀត មិនត្រូវដាំល្ពៅក្រោយពីត្រសក់ ឪឡឹក ត្រឡាច ជាពិសេស ដាំណាំអំបូរ Cucurbitaceae ។ ដើម្បីឱ្យការដាំដុះមានលក្ខណៈងាយស្រួល ត្រូវភ្ជួរហាលដីឱ្យបានច្រើនសារ ហាលដីឱ្យបានយូរថ្ងៃ និងរាស់បំបែកដីឱ្យល្អិត ហើយលើករងដែលមានទទឹង ១៨០ សង់ទីម៉ែត្រ កម្ពស់រង ២៥.៣០ សង់ទីម៉ែត្រ ពង្រាបរងឱ្យស្មើ ហើយកាប់រណ្តៅ ចំកណ្តាលរងជម្រៅ ២០ សង់ទីម៉ែត្រចំងាយរណ្តៅ ១២០ ស.ម បន្ទាប់មក យកជីកម្មជាតិគ្រប់ប្រភេទមកដាក់បាតរណ្តៅឱ្យបានច្រើន ហើយលប់ ដីឱ្យជិតពីលើ ។

### ៣. វិធីសាស្ត្រដាំដុះ

មុននឹងដាំយកគ្រាប់ពូជមកសំអាតជាមុន បន្ទាប់មកដាក់ហាលថ្ងៃឱ្យក្តៅ



ក. ជម្ងឺបង្កឡើងដោយផ្សិត

ជម្ងឺរលួយគល់កូន វាបង្កឡើងដោយភ្នាក់ងារបង្ករោគ៣ ប្រភេទ ៖ Rhi zoctonia solani, Pythium, SPP និង Fusaium SPP ។ ជម្ងឺប្រភេទនេះ មេរោគភាគច្រើនរស់នៅជាមួយគ្រាប់ពូជ និងដីវាអាចឆ្លងនៅពេលកូនល្ពៅចាប់ ផ្តើមដុះពន្លក ធ្វើឱ្យកូនល្ពៅតូចៗ រលួយគល់ ក្នុងរយៈពេល ៤-៧ថ្ងៃក្រោយដាំ ។ ក្នុងករណីមានជម្ងឺប្រភេទនេះកើតឡើងទោះជាវាមិនរលួយគល់ដ៏វាធ្វើឱ្យកូនល្ពៅដុះលូតលាស់ខ្សោយ និងអាចធ្វើឱ្យល្ពៅងាប់ក្នុងពេលចេញផ្កា ។

ជម្ងឺពពាលលឿងស្លឹក វាបង្កឡើងដោយភ្នាក់ងារបង្ករោគឈ្មោះ Pseu-doperonospora cubensis ។ ជម្ងឺប្រភេទនេះតែងតែធ្វើឱ្យស្លឹកល្ពៅលឿងៗ ដុំៗ ហើយពពាលៗក្រោយមកធ្វើឱ្យស្លឹកស្ងួតវាតែងកើតចេញពីស្លឹកក្រោមក្បែរដី រីករាលដាលឡើងមកស្លឹកលើ ក្នុងវគ្គ ចេញផ្កា និងផ្លែ ។

ជម្ងឺផ្សិតម្សៅលើស្លឹក វាបង្កដោយភ្នាក់បង្ករោគឈ្មោះ Erysiphecichor acearum នឹង Sphaerotheca fuligena ។ ដំបូង សង្កេតឃើញចំណុច ម្សៅៗជាដំណក់ៗ នៅលើស្លឹក បន្ទាប់មកចំណុចដំណក់នោះរីកធំទៅៗ ហើយដុះ ចេញនូវម្សៅសៗ ពេញផ្ទៃស្លឹកបន្ទាប់ មកហុយឆ្លងពីចំការមួយទៅចំការមួយធ្វើ ឱ្យស្លឹកស្ងួតអាចធ្វើល្ពៅបន្ថយការបន្តពូជនិងផ្លែមិនរីកធំ មិនទុំពេញលក្ខណៈបាន។



ហិកតាត្រូវប្រើក្នុងកំរិត ២៥-៣០ គីឡូក្រាម ។

- លើកទី៣ យកជី ១៥,១៥,១៥ ចំនួន១០០ គីឡូក្រាមលើផ្ទៃដី ១ ហិកតា មកដាក់ក្បែរគុម្ពចំងាយ ៣០ ស.ម ហើយកប់ដីឱ្យជិតពីលើ ដើម្បីឱ្យល្ពៅផ្លែបានច្រើន ហើយផ្លែលូតលាស់បានល្អរយៈពេល ៤០ ថ្ងៃក្រោយដាំ ។

## ៦. ការស្រោចស្រព

ល្ពៅជាប្រភេទដំណាំធន់ទ្រាំទៅនឹងការកង្វះទឹក ឬភាពរាំងស្ងួត ប៉ុន្តែកាលណាវគ្គចេញផ្កាសំណើមដីមិនគ្រប់គ្រាន់ធ្វើឱ្យថយចុះការ បន្តពូជបាត់បង់បរិមាណផ្លែយ៉ាងច្រើន ។ ការស្រោចស្រពចែកចេញជា ៣ វគ្គធំៗ

- វគ្គលូតលាស់រហូតដល់ចេញផ្កាឈ្មោលៈ វាត្រូវការទឹកជាមធ្យមរយៈពេល ៣-៤ថ្ងៃ ផ្តល់ទឹកម្តង ប៉ុន្តែសំណើមដីមិនត្រូវឱ្យ លើសពី ៦០-៦៥ % ។
- វគ្គចេញផ្កាដល់ផ្លែៈ វគ្គនេះត្រូវផ្តល់ទឹកឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យការបន្តពូជប្រព្រឹត្តទៅបានល្អ ត្រូវរក្សាសំណើមក្នុងកំរិតថេរ ពី ៧០-៧៥ % ។
- វគ្គផ្លែចាស់ និង ទុំៈ ការផ្តល់ទឹកត្រូវថយចុះមកវិញបន្តិចម្តងៗហើយផ្អាកទាំងស្រុងពេលល្ពៅចាប់ផ្តើមប្រមូលផលដំបូង ។

## III. អំពីជម្ងឺ និងសត្វល្អិត

អំពីជម្ងឺសំខាន់ៗ

ល្ពៅក៏ដូចជាដំណាំទៀតដែរ តែងតែទទួលរងនូវជម្ងឺជាច្រើនប្រភេទ ដែលបង្កដោយក្រុមជម្ងឺ និងវីរុស ។

វិធានការការពារ និងកំចាត់: ភ្ជួរហាលដីឱ្យស្ងួតយូរថ្ងៃមុននឹងដាំកំចាត់ស្មៅឱ្យស្អាត ផ្លាស់ប្តូរមុខដាំណាំសំអាតគ្រាប់ពូជមុនដាំ ជ្រើសរើសពូជធន់ទ្រាំ និង ជ្រើសរើសរដូវដាំដុះ ។ ជាពិសេសត្រូវយកគ្រាប់ពូជទៅលាយជាមួយថ្នាំសម្លាប់ផ្សិត មុនដាំ ម្យ៉ាងទៀតយក ថ្នាំសម្លាប់ផ្សិតដូចជា Zineb Mancozeb Orthocid មកលាយទឹកបាញ់ឱ្យជោគក្រោយពីកូនល្ពៅដុះពន្លក ព្រមទាំងបាញ់ទប់ទល់រយៈពេល ពេល ៤-៧ ថ្ងៃម្តងពេលមានរោគសញ្ញាដំបូង ។





ជម្ងឺប្រភេទ នេះកើតឡើងលើដំណាំអំបូរ Cucurbitaceae និង Leguminosae.

ជម្ងឺរលួយក្តឹប: វាបង្កដោយភ្នាក់ងារបង្ករោគឈ្មោះ Choanephora Cucurbitarum, Pythium SPP និងRhizocotonia។ជម្ងឺប្រភេទនេះតែងធ្វើឱ្យមានការរំខានដល់ការបន្តពូជមេរោគផ្សិតធ្វើឱ្យប៉ះពាល់ដល់កេសរញី និង ឈ្មោល ធ្វើឱ្យផ្កាញីមិនអាចបន្តបាន ក្តឹបមិនរីកធំ បន្ទាប់មកប្រែពណ៌ទៅជា លឿងហើយរលួយ ជម្ងឺប្រភេទនេះកើតភាគច្រើននៅរដូវក្តៅហើយមានសំណើម ។



ខ. ជម្ងឺបង្កឡើងដោយវីរុស

មានជម្ងឺវីរុសជាច្រើនប្រភេទដែលកើតនៅលើដំណាំល្ពៅដូចជា ៖

- ជម្ងឺរួញត្រួយៈ ជម្ងឺនេះបង្កឡើងពីរុយស

- ជម្ងឺរួញស្លឹកៈ បង្កឡើងពីខ្ទុងតូចៗ ស្លាបរឹង និងឆ្លងតាមរយៈគ្រាប់ពូជដែលធ្លាប់ទទួលរងការបំផ្លាញពីជម្ងឺប្រភេទនេះពីមុនមកជម្ងឺប្រភេទនេះអាចកើតនៅលើផ្លែល្ពៅ ធ្វើឱ្យប្រែប្រួលទម្រង់សំបកក្រាស់ខុសពីធម្មតាហើយក្រិនមិនធំធាត់ឡើយ ។

- ជម្ងឺតឿ និងពកឬសៈ ជម្ងឺប្រភេទនេះគេតែងសង្កេតឃើញកើតនៅក្នុងវគ្គលូតលាស់ធ្វើឱ្យដើមល្ពៅប្រែពណ៌បៃតងក្រមៅហើយរួញតឿលែងលូលាស់





វិធានការការពារ និងកំចាត់ សត្វល្អិត ជ្រើសរើសពូជសុទ្ធគ្មានសត្វល្អិត និងជម្ងឺបំផ្លាញប្តូរដី នឹងផ្លាស់មុខដំណាំដកដើមដែលមានជម្ងឺវីរ៉ុសទៅដុតចោល

២. អំពីសត្វល្អិតចង្រៃ

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលស៊ីបំផ្លាញនិងចម្លងរោគ ដូចនេះគេចែកចេញជា ២ ផ្នែកគឺៈ

ក. សត្វល្អិត និងភ្នាក់ងារបង្ករោគ សត្វល្អិតចង្រៃប្រភេទនេះមានច្រើនដូចជា ចៃបៃតងជញ្ជក់ស្លឹក មមាចជញ្ជក់ស្លឹក ខ្ទុងពពាលតូចៗ តែងបង្កឱ្យកើតជម្ងឺ វីរ៉ុស ច្រើនប្រភេទ

ខ. សត្វល្អិតបំផ្លាញផ្ទាល់ មានសត្វល្អិតបំផ្លាញជាច្រើនប្រភេទដែលតែងស៊ីស្លឹកផ្កា ផ្លែ និងដើមដូចជា

- អណ្តើកមាសពណ៌លឿងៈ វាស៊ីត្រួយខ្ចីៗ ផ្កាញី និងផ្កាឈ្មោល ធ្វើឱ្យល្ពៅ ថយចុះនូវការលូតលាស់ និងបន្តពូជ ។

- ស្រីងល្ពៅៈ វាជញ្ជក់ស្លឹក និងផ្កា ផ្លែតូចៗធ្វើឱ្យផ្លែលែងធំហើយស្អុយលែងលូតលាស់ ។

- រុយទិចផ្លែៈ រុយប្រភេទតូចនេះទិចបញ្ចូលពងទៅក្នុងផ្លែធ្វើឱ្យផ្លែរលួយមិនធំបាន ។

- ដង្កូវកាត់ដើមៈ ដង្កូវប្រភេទនេះវាកាត់គល់កូនដំណាំខ្ចីៗ ក្នុងវគ្គលូតលាស់ដំបូង។

ដង្កូវចោះផ្លែ: ដង្កូវប្រភេទនេះវាកកេរស៊ីផ្លែ ដើម ស្លឹក គ្រប់វគ្គលូតលាស់ដំណាំ ។

**វិធានការការពារ**

វិធានការតាមបែបជីវសាស្ត្រ: ត្រូវសំអាតស្មៅក្នុងចំការ ដាំឱ្យមានចន្លោះគុម្ព និង ជូរឱ្យបានសមស្របផ្លាស់ប្តូរមុខដំណាំ ហាលដីឱ្យបានយូរខែ ជ្រើសរើសពូជ ដែល សមស្របទៅនឹងតំបន់ដាំដុះ ។

វិធានការតាមបែបគីមី: ត្រូវរោយថ្នាំ Furadan ជុំវិញគល់ អាចយកថ្នាំគីមីលាយទឹកបាញ់ពេល សត្វល្អិតមិនទាន់ពេញវ័យ ។







## IV. ការប្រមូលផល

ការប្រមូលផលធ្វើឱ្យឡើងខុសៗគ្នាទៅតាមប្រភេទពូជ និង តម្រូវការ ទីផ្សារ ។ ផ្លែល្ពៅទុំដំបូងត្រូវប្រមូលមុនគេ ។ លក្ខណៈសំគាល់គឺផ្លែល្ពៅឡើងពណ៌ប្រផេះស្រអាប់សំបករឹង ត្រូវកាត់ផ្លែល្ពៅទាំងទងយកមកទុកលើឆ្នើរមិនប៉ះដីទើបរក្សាបានយូរខែ ។ ជាធម្មតា ល្ពៅក្អែក និងល្ពៅព្នងទិន្នផលមធ្យមពី ១៥-១៦ តោន/ហាត ប៉ុន្តែល្ពៅទ្រូ និងល្ពៅហាបទិន្នផលជាមធ្យមពី ១៨-២០ តោន/ហាត ដើម្បីរក្សាទុកពូជឱ្យបានល្អ គេបេះផ្លែទុំពេញលក្ខណៈពីដើមដែលគ្មានកើតជម្ងឺ មករក្សាទុកពី ១០-១៥ ថ្ងៃបន្ទាប់មកពុះផ្លែ ហើយយកគ្រាប់ មកលាងទឹកឱ្យស្អាត ដាក់ហាលថ្ងៃឱ្យស្ងួតក្នុងថ្ងៃដំបូង តែ២ថ្ងៃបន្ទាប់មកគេត្រូវហាលគ្រាប់ល្ពៅនិងខ្យល់ ស្ងួតមិនឱ្យត្រូវកំដៅថ្ងៃ កាលណា ហាលថ្ងៃក្តៅខ្លាំង ធ្វើឱ្យគ្រាប់ល្ពៅរក្សាភាពរស់ មិនបានកយូរខែ ។បន្ទាប់ពីបានគ្រាប់ហើយ គេត្រូវច្រកនឹងឧបករណ៍ចម្លងកំដៅ និងសំណើម ព្រមទាំងរក្សាទុកនៅកន្លែងស្ងួត ហើយត្រជាក់ធម្មតា ។